# ***បណ្ដឹងវិវាទជំរឿនឆ្នាំ 2020 និងអត្ថន័យរបស់វាសម្រាប់សហគមន៍អាស៊ីអាមេរិក***

បន្ទាប់ពីតុលាការកំពូលសហរដ្ឋអាមេរិកបានរារាំងរដ្ឋបាលពីការបន្ថែមសំណួរនៃភាពជាពលរដ្ឋចូលក្នុងជំរឿនឆ្នាំ 2020 រដ្ឋបាលបានបន្តស្វែងរកមធ្យោបាយផ្សេងទៀតដើម្បីធ្វើឱ្យអន្តរាយដល់ជំរឿនឆ្នាំ 2020 និងរារាំងសហគមន៍ដែលមានប្រវត្តិសាស្ត្រមិនសូវបានរាប់មិនឱ្យទទួលការរាប់ពេញលេញនិងត្រឹមត្រូវ និងត្រូវបានតំណាងនៅក្នុងដំណើរការនយោបាយរបស់យើង។ ស្វែងយល់បន្ថែមអំពីជំរឿនឆ្នាំ 2020 និងមូលហេតុដែលការជំរឿនមានសារៈសំខាន់សម្រាប់សហគមន៍របស់យើងនៅតាមគេហទំព័រ www.CountUsIn2020.org។

## ***ចំណុចសំខាន់ៗ៖***

1. យោងតាមរដ្ឋធម្មនុញ្ញ ជំរឿនមានន័យថាជាការរាប់មនុស្សគ្រប់រូប។ មនុស្សគ្រប់រូបនៅក្នុងសហគមន៍របស់យើងគួរតែត្រូវបានរាប់ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍ឡើយ។
2. ជំរឿនផ្ដល់ផលប៉ះពាល់ដល់ការផ្ដល់ថវិកានិងធនធានដែលសហគមន៍របស់យើងទទួល និងតំណាងនយោបាយនិងសំឡេងរបស់យើងសម្រាប់រយៈពេលដប់ឆ្នាំខាងមុខ។ យើងត្រូវការការរាប់មួយដែលពេញលេញនិងត្រឹមត្រូវដើម្បីទទួលបានចំណែកធនធានស្មើភាពរបស់យើង។
3. ឥឡូវនេះ ការរាប់ជំរឿនឆ្នាំ 2020 បានចប់ហើយ ការិយាល័យជំរឿនត្រូវតែមានពេលវេលាគ្រប់គ្រាន់ដើម្បីដំណើរការទិន្នន័យដែលខ្លួនប្រមូលបាន ហើយកំណត់អត្តសញ្ញាណកំហុសណាមួយ។ ការប្រញាប់ប្រញាល់ដំណើរការទិន្នន័យដើម្បីរាយការណ៍ពីតួលេខចុងក្រោយត្រឹមថ្ងៃទី 31 ខែធ្នូ ទំនងជានឹងមានលទ្ធផលមិនត្រឹមត្រូវសម្រាប់សហគមន៍ដែលមានប្រវត្តិសាស្ត្រមិនសូវបានរាប់។

## ***តើអ្វីទៅជាហានិភ័យក្នុងបណ្ដឹងវិវាទបន្តបន្ទាប់លើជំរឿនឆ្នាំ 2020?***

- បណ្ដឹងមួយចំនួនកំពុងឆ្លងកាត់តុលាការក្នុងការបន្តប្រយុទ្ធដើម្បីជំរឿនប្រជាជនពេញលេញនិងត្រឹមត្រូវ។ បញ្ហាចំបងបីដែលត្រូវបានប្ដឹងរួមមាន៖ (1) ការកាត់បន្ថយការរាប់និងដំណើរការទិន្នន័យ (2) អនុស្សរណៈប្រធានាធិបតីដើម្បីដកជនអន្តោប្រវេសន៍ដែលគ្មានឯកសារពីការបែងចែកពីសមាជិកសភានិង (3) ការបង្កើតឯកសារទិន្នន័យ (ហៅថាប្រជាជនអាយុបោះឆ្នោតឬឯកសារ “CVAP”) ដើម្បីដកពលរដ្ឋដែលមិនមែនជាជនជាតិអាមេរិកចេញពីដំណើរការបែងចែកនៃរដ្ឋឡើងវិញ។ Asian Americans Advancing Justice | AAJC (“Advancing Justice-AAJC”) រួមជាមួយ MALDEF (មូលនិធិការពារផ្នែកច្បាប់និងអប់រំរបស់អាមេរិកម៉ិកស៊ិក)

បច្ចុប្បន្ន
ការប៉ុនប៉ងទាំងនេះកំពុងប្រឈមនឹងអន្តរាយដល់ជំរឿននៅក្នុងតុលាការសហព័ន្ធ។

- ***ការកាត់បន្ថយពេលវេលា៖***
នៅពេលការិយាល័យជំរឿនត្រូវបានបង្ខំឱ្យប្តូរផែនការប្រតិបត្តិការរបស់ខ្លួនដោយសារជំងឺរាតត្បាតសកលកូវីដ-19
ការិយាល័យជំរឿនបានកំណត់ថាខ្លួនត្រូវការបន្តរាប់រហូតដល់ថ្ងៃទី 31 ខែតុលា ឆ្នាំ 2020 ដើម្បីធានានូវការរាប់ពេញលេញនិងត្រឹមត្រូវនិងបន្តដំណើរការទិន្នន័យនៅថ្ងៃទី 30 ខែមេសា ឆ្នាំ 2021។ ទោះយ៉ាងណា ក្នុងខែសីហា
ការិយាល័យជំរឿនបានប្រកាសជាបន្ទាន់ថានឹងកាត់បន្ថយពេលវេលាចាំបាច់ដើម្បីធ្វើជំរឿនដោយបញ្ចប់ការរាប់នៅថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2020
ហើយដំណើរការទិន្នន័យនិងរាយការណ៍ពីការរាប់ចុងក្រោយទៅប្រធានាធិបតីត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020។
- ***អនុស្សរណៈប្រធានាធិបតី៖***
មនុស្សគ្រប់រូបត្រូវតែបានរាប់បញ្ចូលក្នុងជំរឿនប្រជាជនរៀងរាល់ដប់ឆ្នាំម្តង
ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍។ ទោះយ៉ាងណាក៏ដោយ នៅថ្ងៃទី 21 ខែកក្កដា ឆ្នាំ 2020 ប្រធានាធិបតី Trump បានចេញ memo
ដើម្បីដកជនអន្តោប្រវេសន៍ដែលគ្មានឯកសារពីការរាប់ជំរឿនដែលត្រូវបានប្រើដើម្បីរៀបចំកៅអីនៅសភានៅតាមបណ្តារដ្ឋនានា។ រដ្ឋធម្មនុញ្ញបានកំណត់ថា
កៅអីសភាត្រូវតែត្រូវបានបែងចែកដោយផ្អែកលើ
“ចំនួនមនុស្សទាំងអស់នៅក្នុងរដ្ឋនីមួយៗ”
ដូច្នេះរដ្ឋត្រូវបានតំណាងសមាមាត្រទៅនឹងចំនួនប្រជាជន។
ការដកជនអន្តោប្រវេសន៍ដែលគ្មានឯកសារចេញពីចំណែករាប់គឺមិនធ្លាប់មានពីមុនមកទេហើយគឺជាអំពើផ្ទុយពីរដ្ឋធម្មនុញ្ញ
ហើយនឹងផ្លាស់ប្តូរតំណាងនយោបាយឱ្យឆ្ងាយពីកន្លែងដែលមានសហគមន៍ជនអន្តោប្រវេសន៍ច្រើន។
- ***ឯកសារ CVAP៖*** នៅខែកក្កដា ឆ្នាំ 2019
គ្រាន់តែប៉ុន្មានថ្ងៃបន្ទាប់ពីតុលាការកំពូលរារាំងការបន្ថែមសំនួរនៃភាពជាពលរដ្ឋនោះ លោកប្រធានាធិបតី Trump បានចេញ Executive Orderបញ្ជាឱ្យការិយាល័យជំរឿនប្រមូលទិន្នន័យសញ្ជាតិពីទីភ្នាក់ងារសហព័ន្ធនិងរដ្ឋដើម្បីឱ្យរដ្ឋអាចដកពលរដ្ឋមិនមែនជនជាតិអាមេរិកពីការរាប់ប្រជាជនដែលត្រូវបានប្រើដើម្បីគូសផែនទីនីតិប្បញ្ញត្តិរបស់រដ្ឋនៅសង្កាត់ផ្សេងទៀត។ ការប្រើប្រាស់ឯកសារ CVAP ដែលមានទិន្នន័យតែសញ្ជាតិនៅកម្រិតរារាំងនឹងកាត់បន្ថយអំណាចនយោបាយរបស់ជនជាតិអាមេរិកឡាទីននិងអាមេរិកាំងអាស៊ីដែលអាចនឹងរស់នៅក្នុងសហគមន៍ជនអន្តោប្រវេសន៍។

## *តើទិដ្ឋភាពបច្ចុប្បន្នគឺជាអ្វី?*[1]

- ការរាយឈ្មោះសម្រាប់ជំរឿនឆ្នាំ 2020 បានបញ្ចប់នៅថ្ងៃទី 15 ខែតុលា ឆ្នាំ 2020។ តុលាការកំពូលបានកាត់បន្ថយការរាប់នៅពេលដែលមានដីកាបញ្ជាពីតុលាការជាន់ទាបដែលបានបញ្ជាឱ្យការិយាល័យជំរឿនបន្តរាប់ចាប់ពីថ្ងៃទី 31 ខែតុលា តទៅ ដោយសារការិយាល័យជំរឿនបានគ្រោងទុកតាំងពីដើមដំបូងចាប់តាំងមានជំងឺរាតត្បាតសកលកូវីដ-19 មក។
- ឥឡូវនេះ ការរាប់ឈ្មោះបានបញ្ចប់ ហើយការិយាល័យជំរឿនត្រូវដំណើរការទិន្នន័យដែលខ្លួនបានប្រមូល និងរៀបចំតួលេខដើម្បីធ្វើការរាយការណ៍។ "ដំណើរការប្រមូលទិន្នន័យក្រោយ" នេះគឺមានសារៈសំខាន់ណាស់ដើម្បីកំណត់កំហុស និងធានានូវការរាប់ត្រឹមត្រូវ។
- បច្ចុប្បន្នកាលបរិច្ឆេទផុតកំណត់សម្រាប់ការិយាល័យជំរឿនដើម្បីដាក់ការរាប់ចុងក្រោយឆ្នាំ 2020 ជូនលោកប្រធានាធិបតីគឺថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យជំរឿនបានបញ្ជាក់ម្តងហើយម្តងទៀតពីមុនមកថាមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីបំពេញតាមកាលបរិច្ឆេទផុតកំណត់ទេ ហើយវាត្រូវការរហូតដល់ថ្ងៃទី 30 ខែមេសា ឆ្នាំ 2021 ដើម្បីធានាថា វាអាចអនុវត្តជំហានដំណើរការទិន្នន័យចាំបាច់ទាំងអស់។
- បណ្តឹងជាច្រើនបានជម្រុញឱ្យទុកកាលបរិច្ឆេទផុតកំណត់ថ្ងៃទី 31 ខែធ្នូ ទុកមួយឡែកសិន។ ចៅក្រមសហព័ន្ធនៅរដ្ឋកាលីហ្វ័រញ៉ាបានយល់ព្រមនិងបានកំណត់កាលបរិច្ឆេទផុតកំណត់ថ្ងៃទី 30 ខែមេសា ឆ្នាំ 2021 សម្រាប់ធ្វើការរាយការណ៍។ រដ្ឋាភិបាលបានសម្រេចសេចក្តីប្តឹងឧទ្ធរណ៍នេះ ហើយសេចក្តីសម្រេចត្រូវបានផ្អាកខណៈពេលបណ្តឹងឧទ្ធរណ៍ស្ថិតនៅក្នុងការសម្រេចចិត្តនៅឡើយ។ នេះមានន័យថា ឥឡូវនេះការិយាល័យជំរឿនមានភារកិច្ចរាយការណ៍អំពីការរាប់ចំនួនបែងចែកត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020 និងអនុវត្តក្រោយដំណើរការក្នុងរយៈពេលតិចជាងពាក់កណ្តាលដូចដែលបានគ្រោងទុក។
- យោងតាមអនុស្សរណៈរបស់ប្រធានាធិបតី នៅថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 2020 ក្រុមចៅក្រមនៃសហព័ន្ធចំនួនបីនៅទីក្រុងញូវយ៉កបានសម្រេចថា ការមិនរាប់បញ្ចូលជនអន្តោប្រវេសន៍ដែលគ្មានឯកសារក្នុងការរាប់ចំនួនសមាជិកសភាគឺខុសច្បាប់។ រដ្ឋបាល Trump បានប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនេះ ហើយតុលាការកំពូលគ្រោងនឹងបើកសវនាការរឿងក្តីនេះនៅថ្ងៃទី 30 ខែវិច្ឆិកា។

---

[1] បានធ្វើចុងក្រោយនៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២០ ។ ខណៈដែលការវិវាទដំណើរការ វានឹងមានការផ្លាស់ប្តូរក្នុងកាលៈទេសៈនៅកន្លែងដែលការងារជាក់ស្តែងត្រូវបានធ្វើ។

## *តើនេះមានន័យយ៉ាងដូចម្ដេចសម្រាប់សហគមន៍អាស៊ីអាមេរិក ជនជាតិដើមហាវ៉ៃ និងអ្នកកោះប៉ាស៊ីហ្វិក?*

- សព្វថ្ងៃនេះ មានជនជាតិអាស៊ីអាមេរិកម្នាក់ក្នុងចំណោមប្រាំនាក់ និងជនជាតិដើមហាវ៉ៃម្នាក់ក្នុងចំណោមបីនាក់និងអ្នកកោះប៉ាស៊ីហ្វិករស់នៅសង្កាត់ដែលពិបាករាប់ និងមានប្រវត្តិសាស្រ្តមិនសូវបានរាប់នៅក្នុងជំរឿន។ ការរាប់ពេញលេញនិងត្រឹមត្រូវគឺចាំបាច់គ្រប់យ៉ាងរាប់ចាប់ពីការថែទាំសុខភាពនិងការអប់រំរហូតដល់លំនៅដ្ឋាននិងការដឹកជញ្ជូនក្នុងរយៈពេលដប់ឆ្នាំខាងមុខ។
- ទោះបីការរាប់ជំរឿនបានបិទក៏ដោយក៏កិច្ចប្រឹងប្រែងរបស់យើងដើម្បីធានាថាសហគមន៍របស់យើងត្រូវបានតំណាងពេញលេញនៅក្នុងជំរឿន និងដើម្បីធានាសន្តិសុខក្នុងការទទួលបានមូលនិធិនិងអំណាចនយោបាយដែលបានពីជំរឿនមិនទាន់បញ្ចប់ទេ។ ការប្រញាប់ប្រញាល់ដំណើរការទិន្នន័យដើម្បីរាយការណ៍ពីតួលេខចុងក្រោយត្រឹមថ្ងៃទី 31 ខែធ្នូនឹងបណ្តាលឱ្យមានលទ្ធផលរាប់មិនត្រឹមត្រូវសម្រាប់សហគមន៍ដែលប្រវត្តិសាស្រ្តមិនសូវបានរាប់។
- រដ្ឋធម្មនុញ្ញមានភាពច្បាស់លាស់ថា ជំរឿនគួរតែរាប់ “ចំនួនមនុស្សទាំងអស់នៅក្នុងរដ្ឋនីមួយៗ។” ការមិនរាប់បញ្ចូលសមាជិកដែលគ្មានឯកសារនៅក្នុងសហគមន៍របស់យើងពីចំនួនដើម្បីបែងចែក កៅអីសភានឹងមានផលប៉ះពាល់យ៉ាងច្រើនដល់ការតំណាងផ្នែកនយោបាយនៃសហគមន៍ជនអន្តោប្រវេសន៍ និងសហគមន៍ដែលមានច្រើនពូជសាសន៍ទៀត។
- Advancing Justice-AAJC សហការជាមួយ MALDEF បន្តប្រយុទ្ធប្រឆាំងនឹងបញ្ហាទាំងនេះនៅក្នុងតុលាការដើម្បីធានាថា សហគមន៍របស់យើងត្រូវបានតំណាង។